ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ១៨១នាក់ និងមានករណីជាសះស្បើយ ចំនួន ៤០នាក់ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤៤៤ | ១២២ | ៣២២ | អ្នកឆ្លងថ្មី៖ **០២នាក់** |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩២ | ៧០ | ២២ | អ្នកឆ្លងថ្មី៖ **០១នាក់** |
| | ១.៣.ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ៤១៦០ | ២៤០៤ | ១៧៥៦ | អ្នកឆ្លងថ្មី៖ **១៧៨នាក់** |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៤៦៩៦** | **២៥៩៦** | **២១០០** | អ្នកឆ្លងថ្មី៖ **១៨១នាក់** |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤៣១ | ១១៦ | ៣១៥ | អ្នកជាថ្មី៖ ០នាក់ |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩១ | ៦៩ | ២២ | អ្នកជាថ្មី៖ ០នាក់ |
| | ២.៣. ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ១៧៣០ | ៨៥៣ | ៨៧៧ | អ្នកជាថ្មី៖ **៤០នាក់** |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **២២៥២** | **១០៣៨** | **១២១៤** | អ្នកជាថ្មី៖ **៤០នាក់** |
| ៣. | **ករណីអ្នកស្លាប់៖** | | | | |
| | ៣.១.អ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ | ៣៣ | ១៦ | ១៧ | អ្នកស្លាប់ថ្មី៖ **០៣នាក់** |
| | **សរុបករណីអ្នកស្លាប់** | **៣៣** | **១៦** | **១៧** | |
| ៤. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

| | | | |
|---|---|---|---|
| ៤.១. មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និង ហង់សិន | ៤៦ | ២៥ | ២១ |
| ៤.២. មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ២៧ | ១០ | ១៧ |
| ៤.៣. មណ្ឌលសុខភាពចាក់អង្រែ | ៤៣ | ២៥ | ១៨ |
| ៤.៤. មន្ទីរពេទ្យខេត្តប៉ៃលិន | ០១ | ០១ | ០ |
| ៤.៥. មន្ទីរពេទ្យបង្អែក ខេត្តព្រះសីហនុ | ៦៨ | ៤៤ | ២៤ |
| ៤.៦. សណ្ឋាគារសម័យថ្មីអន្តរជាតិ ខេត្តព្រះសីហនុ | ៣៦ | ២៨ | ០៨ |
| ៤.៧. មន្ទីរពេទ្យបង្អែកជ័យជំនះខេត្ត កណ្ដាល | ៦៩ | ៤៥ | ២៤ |
| ៤.៨. មណ្ឌលព្យាបាលស្រុកកោះធំ ខេត្ត កណ្ដាល | ១៣ | ០២ | ១១ |
| ៤.៩. សណ្ឋាគារក្រោតនុករាជធានីភ្នំពេញ | ៣១២ | ១៧៩ | ១៣៣ |
| ៤.១០. មន្ទីរពេទ្យខេត្តកោះកុង | ១៨ | ០២ | ១៦ |
| ៤.១១មន្ទីរពេទ្យបង្អែកបារាយណ៍-សន្ទុក ខេត្តកំពង់ធំ | ០១ | ០ | ០១ |
| ៤.១២. មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង | ២៨ | ១៤ | ១៤ |
| ៤.១៣. មន្ទីរពេទ្យខេត្តកំពង់ចាម | ០៧ | ០៥ | ០២ |
| ៤.១៤. មន្ទីរពេទ្យខេត្តសៀមរាប | ១៣ | ០៥ | ០៨ |
| ៤.១៥. មន្ទីរពេទ្យខេត្តកំពត | ០៣ | ០៣ | ០ |
| ៤.១៦. មន្ទីរពេទ្យខេត្តតាកែវ | ១៣ | ០៦ | ០៧ |
| ៤.១៧. មន្ទីរពេទ្យបង្អែកខេត្តកែប | ០១ | ០ | ០១ |
| ៤.១៨. មន្ទីរពេទ្យខេត្តត្បូងឃ្មុំ | ០៩ | ០៥ | ០៤ |
| ៤.១៩. មន្ទីរពេទ្យស្វាយជ្រុំ ខេត្តស្វាយរៀង | ១១៤ | ៣៨ | ៧៦ |
| ៤.២០. មណ្ឌលព្យាបាលកូវីដ-១៩ ក្រុងបាវិត | ៤៥ | ១៥ | ៣០ |
| ៤.២១. មន្ទីរពេទ្យកុមារជាតិ | ០១ | ០១ | ០ |
| ៤.២២. មន្ទីរពេទ្យហ្លួងម៉ែ | ១៤៦ | ៧៧ | ៦៩ |
| ៤.២៣. មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង | ០២ | ០ | ០២ |
| ៤.២៤. មន្ទីរពេទ្យខេត្តពោធិ៍សាត់ | ០៧ | ០២ | ០៥ |
| ៤.២៥. មន្ទីរពេទ្យខេត្តក្រចេះ | ០១ | ០១ | ០ |
| ៤.២៦. មន្ទីរពេទ្យខេត្តព្រះវិហារ | ០១ | ០១ | ០ |
| ៤.២៧. ព្យាបាលនៅផ្ទះ | ១៧ | ១០ | ០៧ |
| ៤.២៨. រងចាំបញ្ជូនទៅកន្លែងសម្រាក | ១៣៦៤ | ៩៩៦ | ៣៦៨ |
| **សរុបអ្នកកំពុងសម្រាកព្យាបាល** | **២៤០៦** | **១៥៤០** | **៨៦៦** |

**២. ព័ត៌មានប្រចាំថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១**

**ក. មានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ សរុបចំនួន ១៨១នាក់**

**ក.១. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០២នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- កុមារីជនជាតិខ្មែរ អាយុ ០៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំកញ្ចំ ស្រុកពាមរាំង ខេត្តព្រៃវែង ជាអ្នកធ្វើដំណើរមកពីសហរដ្ឋអាមេរិក បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។
- បុរសជនជាតិខ្មែរ អាយុ ៣៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ជាអ្នកធ្វើដំណើរមកពីប្រទេសឥណ្ឌា បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។

**សម្គាល់៖** លទ្ធផលធ្វើតេស្តវត្ថុសំណាក របស់បុគ្គលទាំង **០២នាក់**ខាងលើនេះ ផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ វិជ្ជមានវីរុសកូវីដ-១៩។ អ្នកជំងឺ **០២នាក់** ខាងលើនេះក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលទទួលបានកន្លែងសម្រាកព្យាបាល។

**ក.២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០១នាក់ ដែលជាពលករធ្វើដំណើរមកពីប្រទេសថៃ**

- ស្ត្រីជនជាតិខ្មែរ អាយុ ៥០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត ជាអ្នកធ្វើដំណើរមកពីប្រទេសថៃ មកដល់កម្ពុជានៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១។ បច្ចុប្បន្នអ្នកជំងឺរូបនេះត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពត។

**ក.៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ១៧៨នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ**

- បុរសជនជាតិខ្មែរ អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។
- ស្ត្រីជនជាតិខ្មែរ អាយុ ៤៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។
- ស្ត្រីជនជាតិខ្មែរ អាយុ ៧១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ **០៣នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល។

- ស្ត្រីជនជាតិខ្មែរ អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំក្រញូងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តក្រចេះ។

- ស្ត្រីជនជាតិខ្មែរ អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ពោធិ៍ ក្រុងត្បែងមានជ័យ ខេត្តព្រះវិហារ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តព្រះវិហារ។

- បុរសជនជាតិខ្មែរ អាយុ ២១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងសៀមរាប ខេត្តសៀមរាប។
- ស្ត្រីជនជាតិខ្មែរ អាយុ ២១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងសៀមរាប ខេត្តសៀមរាប។
- ស្ត្រីជនជាតិខ្មែរ អាយុ ៥០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងសៀមរាប ខេត្តសៀមរាប។
- បុរសជនជាតិខ្មែរ អាយុ ៥០ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ក្រុងសៀមរាប ខេត្តសៀមរាប។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ **០៤នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប។

- បុរសជនជាតិខ្មែរ អាយុ ២១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តតាកែវ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែននុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

**ករណីវិជ្ជមាននៅ ខេត្តព្រះសីហនុ សរុបចំនួន ០៨នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ០៧នាក់ ស្ត្រី ០៥នាក់ និងបុរស ចំនួន ០២នាក់

➢ ជនជាតិវៀតណាម ចំនួន ០១នាក់ ជាស្ត្រី

បច្ចុប្បន្នអ្នកជំងឺ **០៨នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។

**ករណីវិជ្ជមាននៅ ខេត្តព្រៃវែង សរុបចំនួន ០៦នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ០៦នាក់ ស្ត្រី ០១នាក់ និងបុរស ចំនួន ០៥នាក់

បច្ចុប្បន្នអ្នកជំងឺ **០៦នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តព្រៃវែង។

**ករណីវិជ្ជមាននៅ ខេត្តស្វាយរៀង សរុបចំនួន ១៤នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ១០នាក់ ស្ត្រី ០៣នាក់ និងបុរស ចំនួន ០៧នាក់

បច្ចុប្បន្នអ្នកជំងឺ **១០នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលព្យាបាលកូវីដ-១៩ ក្រុងបាវិត។

➢ ជនជាតិខ្មែរ ចំនួន ០៣នាក់ ស្ត្រី ០២នាក់ និងបុរស ចំនួន ០១នាក់

➢ ជនជាតិឥណ្ឌូនេស៊ី ចំនួន ០១នាក់ ជាបុរស

បច្ចុប្បន្នអ្នកជំងឺ **០៤នាក់** ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យស្វាយជ្រុំ ខេត្តស្វាយរៀង។

**ករណីវិជ្ជមាននៅ រាជធានីភ្នំពេញ សរុបចំនួន ១៤០នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកវិជ្ជមានជំងឺកូវីដ-១៩ ៖**

➢ ជនជាតិខ្មែរ ចំនួន ១៣៩នាក់ ស្ត្រី ៧៦នាក់ និងបុរស ចំនួន ៦៣នាក់

➢ ជនជាតិបារាំង ចំនួន ០១នាក់ ជាបុរស

មានអ្នកជំងឺ **០២នាក់** ក្នុងចំណោមអ្នកជំងឺខាងលើនេះ បានទទួលមរណៈភាពកាលនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១។

អ្នកជំងឺចំនួន **១៣៨នាក់** ខាងលើក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលទទួលបានកន្លែងសម្រាកព្យាបាល។

**ខ. ករណីជាសះស្បើយ ៖ សរុបចំនួន ៨០នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ:**

- បុរសជនជាតិចិន អាយុ ២២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល។
- បុរសជនជាតិចិន អាយុ ៣១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមណ្ឌលព្យាបាលស្រុកកោះធំ ខេត្តកណ្តាល។

- កុមារជនជាតិខ្មែរ អាយុ ១៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។
- កុមារជនជាតិខ្មែរ អាយុ ០៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តសៀមរាប។

- បុរសជនជាតិខ្មែរ អាយុ ៨២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- បុរសជនជាតិខ្មែរ អាយុ ៥២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់បឹងកក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**សម្គាល់៖** បុគ្គល **០២នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**ករណីជានៅ មន្ទីរពេទ្យហ្លួងម៉ែ ចំនួន ៣៤នាក់ ក្រសួងសូមធ្វើការសរុបជូនចំនួនអ្នកជាសះស្បើយ៖**

- ជនជាតិខ្មែរ ចំនួន ៣២នាក់ ស្ត្រី ១៤នាក់ និងបុរស ១៨នាក់
- ជនជាតិចិន ចំនួន ០២នាក់ ស្ត្រី ០១នាក់ និងបុរស ០១នាក់

បុគ្គល **៣៤នាក់**ខាងលើនេះ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីសណ្ឋាគារសេម៉យថ្មីអន្តរជាតិ ខេត្តព្រះសីហនុ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ធីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ មន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប និងមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៃមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ២កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩